ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៦.១៣.០១៧-០០៧៥ ប.ក.ព.ក.ម.

ថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែធ្នូ គ.ស. ២០១៧

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៤ ឆ្នាំ២០១៧ តួនាទីរបស់បច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា

ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៤ ឆ្នាំ២០១៧ ស្តីពី "តួនាទីរបស់បច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា" ក្រោមអធិបតីភាពរបស់លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា។ គោលបំណងនៃសន្និសីទនេះ គឺដើម្បីរួមចំណែកអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅកម្ពុជា លើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ និងលើកកម្ពស់ការពិភាក្សារវាងភាគីពាក់ព័ន្ធក្នុងចំណោមអ្នកស្រាវជ្រាវ អ្នកជំនាញ និងអ្នករៀបចំគោលនយោបាយ ជាពិសេស ដើម្បីពិភាក្សានិងចែករំលែកចំណេះដឹង អំពីសារៈសំខាន់និងការរីកចម្រើនយ៉ាងរហ័សនៃការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងវិស័យហិរញ្ញវត្ថុ (Fintech) និងដើម្បីរួមចំណែកក្នុងគោលនយោបាយលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា។

អង្គសន្និសីទបានពិភាក្សាលើប្រធានបទចំនួន៣ គឺ ៖ i/- ការប្រើប្រាស់ទូរស័ព្ទចល័ត និងបរិយាប័ន្នហិរញ្ញវត្ថុ ii/- វឌ្ឍនភាពនិងឥទ្ធិពលនៃបច្ចេកវិទ្យាលើការទទួលបានសេវាហិរញ្ញវត្ថុ និង iii/- តួនាទីរបស់បច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ៖ "បទពិសោធន៍ពីប្រទេសឥណ្ឌា"។ សន្និសីទនេះមានការអញ្ជើញចូលរួមពីតំណាងមកពីក្រសួងពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ សេដ្ឋវិទូ និស្សិត និងសាធារណជន ប្រមាណជាង២៥០ នាក់។

សន្និសីទនេះប្រព្រឹត្តទៅដោយជោគជ័យ ព្រមទាំងមានការចែករំលែកនូវបទពិសោធន៍និងគន្លឹះសំខាន់ៗដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាជ្ញាធរ និងភាគីពាក់ព័ន្ធ ព្រមទាំងផ្តល់ជាធាតុចូលយ៉ាងសំខាន់សម្រាប់ការរៀបចំគោលនយោបាយប្រកបដោយភាពគ្រប់ជ្រុងជ្រោយ សំដៅរួមចំណែកធានាឱ្យបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

ដើម្បីបន្តលើកកម្ពស់ការស្រាវជ្រាវប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា គ្រោងនឹងរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី៥ នៅឆ្នាំ២០១៨ ខាងមុខទៀត។ ៕

ព្រះរាជាណាចក្រកម្ពុជា
ធនាគារជាតិនៃកម្ពុជា

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh